# សហគមន៍ខ្មែរកម្ពុជាក្រោម

## KHMER KAMPUCHEA KROM COMMUNITY
## LA COMMUNAUTÉ DU KHMER KAMPUCHEA KROM

លេខ ០០៣១/០៧ ស.ខ.ក.ក.

### លិខិតឆ្លើយតបចំពោះសេចក្ដីបំភ្លឺ

របស់

### សម្ដេចអគ្គមហាសង្ឃរាជាធិបតី សម្ដេចព្រះមហាសង្ឃរាជនៃព្រះរាជាណាចក្រកម្ពុជា

យោងលិខិតបំភ្លឺលេខ៣៨/០៧ ម.ស.រ.ស.ប. ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៧ ករណីចាប់ផ្សឹកព្រះតេជគុណទឹម សាខន ព្រះចៅអធិការវត្តភ្នំដិនខាងជើង ឃុំភ្នំដិន ស្រុកគិរីវង់ ខេត្តតាកែវ របស់សម្ដេចព្រះមហាសង្ឃរាជទេព វង្ស, សហគមន៍ខ្មែរកម្ពុជាក្រោមមានសេចក្ដីសោកស្ដាយយ៉ាងខ្លាំងចំពោះខ្លឹមសារដែលបានស្រាយដោយពុំបានឆ្លុះបញ្ចាំងសច្ចធម៌ និងធម៌វិន័យក្នុងព្រះពុទ្ធសាសនាឡើយ។

ក្នុងនាមសហគមន៍ខ្មែរកម្ពុជាក្រោម និងក្នុងនាមខ្ញុំផ្ទាល់ដែលជាពុទ្ធសាសនិកជនម្នាក់ដែលតែងតែគោរពព្រះពុទ្ធសាសនាយ៉ាងខ្ជាប់ខ្ជួន សូមព្រះអនុញ្ញាតនិងអនុញ្ញាតពីសម្ដេច ទ្រង់ ឯកឧត្ដម លោកជំទាវ លោក លោកស្រី ដែលជាពុទ្ធសាសនិកជន និងជនរួមជាតិជាសាសនូបត្ថម្ភក៏ ទាំងអស់ធ្វើនូវការកត់សំគាល់ដូចខាងក្រោមៈ

*ចំណុចទី១:* លិខិតរបស់សម្ដេចព្រះសង្ឃរាជទេព វង្សបានសរសេរថា ការចាប់ផ្សឹកព្រះតេជគុណទឹម សាខន កាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៧ គឺធ្វើឡើងតាមសំណូមពរអ្នកច្បាប់ និងអនុវត្តតាមមាត្រាទី៣៧ និងមាត្រាទី៤៣នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាដោយបានចោទប្រកាន់ថា ព្រះតេជគុណទឹម សាខន មិនបានចាត់ទុកព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ និងដឹកនាំធ្វើបាតុកម្មចំនួន២លើកប្រឆាំងនឹងមិត្តភាព សាមគ្គីភាពកម្ពុជា-វៀតណាមគឺការធ្វើបាតុកម្មខុសច្បាប់។ ការលើកឡើងបែបនេះ មិនមែនជាសមត្ថកិច្ចរបស់សម្ដេចសង្ឃរាជ ហើយព្រះអង្គកំពុងតែរំលោភទៅលើអធិបតេយ្យរបស់រដ្ឋាភិបាល ពីព្រោះការអនុញ្ញាតឬមិនអនុញ្ញាតក្នុងការធ្វើបាតុកម្មនោះក្នុងឯកសណ្ឋានជាសាសនាក្ដី ជាយោធាក្ដី ឬជាស៊ីវិលក្ដី ជាសមត្ថកិច្ចផ្ដាច់មុខរបស់ស្ថាប័នរដ្ឋ រួមទាំងកិច្ចការសាសនាផងដែរ។ ពុទ្ធសាសនាជាសាសនារបស់រដ្ឋ មានន័យថាកិច្ចការសាសនា ជាសមត្ថកិច្ចផ្ដាច់មុខរបស់រដ្ឋាភិបាលក្នុងការការពារសិទ្ធិ សេរីភាព ជំនឿសាសនា និងប្រតិបត្តិកិច្ចការសាសនា។ ពុទ្ធចក្រមិនអាចរំលោភលើសិទ្ធិអំណាចរដ្ឋាភិបាលដាច់ខាត។ ក្នុងវិភាគផ្លូវច្បាប់ ប្រជាពលរដ្ឋខ្មែរគ្រប់រូប ទោះបីជាពុទ្ធសាសនិកក្ដី គ្រីស្ទបរិស័ទក្ដី ឥស្លាមក្ដី ត្រូវស្ថិតក្រោមអំណាចតុលាការដើម្បីបកស្រាយ និងកាត់សេចក្ដីតាមផ្លូវច្បាប់ (មាត្រា១៣០រដ្ឋធម្មនុញ្ញ)។ ផ្ទុយមកវិញ ថ្នាក់ដឹកនាំសង្ឃអង្គណាដែលកាត់សេចក្ដីទៅលើសិទ្ធិ សេរីភាពរបស់បុគ្គលគឺជាការរំលោភសមត្ថកិច្ចតុលាការដែលបានធានាដោយរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន។

ការពិតជាក់ស្ដែងព្រះតេជគុណទឹម សាខនជាសង្ឃក្នុងពុទ្ធសាសនាដែលបានគោរពធម៌វិន័យយ៉ាងត្រឹមត្រូវ ពិសេសព្រះអង្គបានកសាងកុដិ សាលា ព្រះវិហារទុកជាសម្បត្តិសាសនាយ៉ាងច្រើន។ នេះបញ្ជាក់ឲ្យឃើញច្បាស់ថាព្រះអង្គបានបំពេញតួនាទីក្នុងពុទ្ធសាសនាយ៉ាងល្អប្រសើរ។ ចំពោះការដឹកនាំធ្វើបាតុកម្មវិញ ព្រះអង្គមិនដែលបានចូលរួមម្ដងណាឡើយ។ នេះជាការចោទប្រកាន់មួលបង្កាច់ខុសពីការពិតទាំងស្រុង។

*ចំណុចទី២:* សម្ដេចព្រះសង្ឃរាជទេព វង្សចោទព្រះតេជគុណទឹម សាខនថាបានបំផ្លាញពុទ្ធសាសនាឥមករា និងបំបែកបំបាក់សាមគ្គីសង្ឃដែលក្នុងព្រះវិន័យហៅថា“សង្ឃភេទ”ជាទោសបារាជិក និងព្រហ្មទណ្ឌ ត្រូវតែលាចាកសិក្ខាបទ ។

ចំណុចនេះសម្ដេចព្រះសង្ឃរាជកំពុងតែបកស្រាយច្រឡំបល់ ប្រាសចាកព្រះវិន័យក្នុងពុទ្ធសាសនាជាសាសនារបស់ព្រះពុទ្ធជាម្ចាស់ដែលបានត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង មិនមែនព្រះពុទ្ធសាសនាឥមករាទេ។ រីឯព្រះសោណ-ត្ថេរនិងឧត្តរត្ថេរ ដែលបានផ្សព្វផ្សាយព្រះពុទ្ធសាសនា មកតំបន់សុវណ្ណភូមិ(កម្ពុជា)មុនគេ ក៏មិនបានចាត់ទុកថា

ជាពុទ្ធសាសនាសោណាត្ថេរនិងឧត្តរត្ថេរដែរ។ ចំណែករដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាមាត្រា៤៣ ក៏មិនបានចែងថា ពុទ្ធសាសនាពីមករាជាសាសនារបស់រដ្ឋដែរ, បានចែងត្រឹមតែថាព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋប៉ុណ្ណោះ ។ ចំពោះការចោទប្រកាន់ថាព្រះតេជគុណទឹម សាខនមានទោសសង្ឃភេទត្រូវចាប់ផ្សឹកនោះ រឹតតែខុសច្បាប់វិន័យក្នុងព្រះពុទ្ធសាសនាថែមទៀត។

សង្ឃភេទមានន័យថាបំបែកសង្ឃ។ ពាក្យថាបំបែកសង្ឃក្នុងព្រះវិន័យសំដៅព្រះសង្ឃដែលគង់នៅក្នុងអាវាស(វត្ត)ជាមួយគ្នាដែលភាគីម្ខាងៗមានគ្នាចំនួន៤អង្គឡើងទៅ ដែលហៅថាគ្រប់ចំនួនសង្ឃហើយបានញុះញង់ក្រុមព្រះសង្ឃទាំងនោះមិនឲ្យឡើងធ្វើឧបោសថកម្មជាមួយគ្នាទើបហៅថាសង្ឃភេទ ហើយទោសសង្ឃភេទនេះមិនមែនត្រូវអាបត្តិបារាជិកទេ គឺត្រូវអាបត្តិសង្ឃាទិសេសសិក្ខាបទទី១០។ ផ្ទុយមកវិញ ភិក្ខុសង្ឃណាមួយក្នុងព្រះពុទ្ធសាសនា មិនថាសម្តេចសង្ឃរាជ សង្ឃនាយក ឬសង្ឃរាជាគណៈទេដែលបានចោទប្រកាន់ភិក្ខុសង្ឃដទៃថាត្រូវអាបត្តិបារាជិក ដោយគ្មានមូលឬដោយលេសផ្សេងៗ ភិក្ខុអង្គនោះ(ដើមចោទ)ត្រូវអាបត្តិសង្ឃាទិសេសក្នុងសិក្ខាបទទី៨-៩ មិនអាចស្ថិតនៅជាភិក្ខុភាវៈពេញលក្ខណៈតទៅទៀតទេ ហើយមិនអាចធ្វើជាព្រះឧបជ្ឈាយ៍ឬនិមន្តចូលរួមធ្វើសង្ឃកម្មផ្សេងៗបានឡើយ។

*ចំណុចទី៣:* ក្នុងលិខិតបានសរសេរថា ព្រះតេជគុណទឹម សាខនបានសំណូមពរឲ្យបញ្ជូនព្រះអង្គទៅស្រុកកំណើត(កម្ពុជាក្រោម)វិញ ដោយមានភ្ជាប់លិខិតស្នើសុំរបស់ព្រះតេជគុណទឹម សាខនមកជាមួយផង។

ចំណុចនេះរឹតតែមិនសមហេតុសមផលថែមទៀត ពីព្រោះពាក្យពេចន៍ក្នុងលិខិតនោះពុំបានប្រើពាក្យសង្ឃស័ព្ទឲ្យបានត្រឹមត្រូវទេ ហើយមិនមែនជាអក្សររបស់ព្រះតេជគុណទឹម សាខនទៀតផង។ នៅក្នុងលិខិតបំភ្លឺរបស់សម្តេចព្រះសង្ឃរាជទេព វង្សបានប្រើពាក្យថា *“ទណ្ឌិត”* ហេតុដូចម្តេចមិនបញ្ជូនទៅតុលាការជំនុំជំរះ, មិនតែប៉ុណ្ណោះបែរជាធ្វើតាមសំណូមពររបស់អ្នកទោសទៅវិញ? តើសំអាងទៅលើច្បាប់ណានៅព្រះរាជាណាចក្រកម្ពុជាយើងនេះ? តើព្រះតេជគុណទឹម សាខនចង់ទៅកម្ពុជាក្រោមធ្វើអ្វី បើឪពុកម្តាយបងប្អូនរបស់ព្រះអង្គនៅកម្ពុជាទាំងអស់នោះ? តើព្រះតេជគុណទឹម សាខនចង់ទៅកម្ពុជាក្រោមធ្វើអ្វី បើព្រះអង្គត្រូវបានសម្តេចសង្ឃចោទថាធ្វើសកម្មភាពប្រឆាំងយួនរហូតដល់នាំឲ្យខូចដល់មិត្តភាព សាមគ្គីភាពកម្ពុជា-វៀតណាមនោះ? តើព្រះអង្គឆោតល្ងង់រហូតដល់ចង់ទៅស្លាប់ក្នុងកណ្តាប់ដៃយួនដោយគ្មានការតស៊ូឬ?

ដូច្នេះ សហគមន៍ខ្មែរកម្ពុជាក្រោមមិនអាចទទួលយកសេចក្តីបំភ្លឺរបស់សម្តេចព្រះសង្ឃរាជទេព វង្សបានឡើយ ហើយសូមអំពាវនាវសម្តេចព្រះសង្ឃរាជផ្ទាល់ដែលបានអះអាងថាខ្លួនជាអ្នកទទួលខុសត្រូវចំពោះករណីចាប់ផ្សឹកព្រះតេជគុណទឹម សាខនតាមសេចក្តីបំភ្លឺក្នុងលិខិតរបស់ព្រះអង្គនោះ មេត្តាចាត់វិធានការនាំយកព្រះតេជគុណទឹម សាខនមកវិញ យ៉ាងហោចណាស់សូមប្រាប់ទីកន្លែងដែលព្រះតេជគុណទឹម សាខនគង់នៅពិតប្រាកដដល់សាធារណជនឲ្យបានឆាប់បំផុត។

សូមសម្តេចព្រះមហាសង្ឃរាជ ព្រះសង្ឃរាជាគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី ជនរួមជាតិ និងពុទ្ធបរិស័ទទាំងអស់ ព្រះមេត្តា និងមេត្តាជ្រាបតាមការគួរ។

*រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៧*

**នាយកប្រតិបត្តិសហគមន៍ខ្មែរកម្ពុជាក្រោម**

ថាច់ សេដ្ឋា

**អតីតសមាជិកព្រឹទ្ធសភា**

**<u>ចម្លងជូន:</u>**

-ខុទ្ទកាល័យព្រះមហាក្សត្រ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងធម្មការនិងសាសនា
“ដើម្បីផ្សព្វផ្សាយ”
-ឯកសារ-កាលប្បវត្តិ